ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១១៦ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួងរៀបចំកិច្ចប្រជុំវេទិកាសេដ្ឋកិច្ចពិភពលោកស្តីពីអាស៊ាន ឆ្នាំ២០១៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- លិខិតលេខ ៧០៧ សជណ ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល។

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងរៀបចំកិច្ចប្រជុំវេទិកាសេដ្ឋកិច្ចពិភពលោកស្តីពីអាស៊ាន ឆ្នាំ២០១៧ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ស៊ុន ចាន់ថុល** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | ប្រធាន |
| ២- ឯកឧត្តម **ប៉ាន សូរស័ក្តិ** | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣- ឯកឧត្តម **តៅ គឹមហួន** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៤- ឯកឧត្តម **ហ៊ើង ថូរ៉ាក់ស៊ី** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥- លោក **សែន សិលា** | ទីប្រឹក្សាផ្ទាល់**សម្តេចតេជោនាយករដ្ឋមន្ត្រី** | សមាជិក |

៦- ឯកឧត្តម នាយឧត្តមសេនីយ៍ **ឯម សំអាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក
៧- ឯកឧត្តម នាយឧត្តមសេនីយ៍ **ម៉ឹង សំផន** រដ្ឋលេខាធិការក្រសួងការពារជាតិ សមាជិក
៨- ឯកឧត្តម **លុយ ដាវីត** រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក
៩- ឯកឧត្តម **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ជាអនុប្រធានប្រចាំការនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិសមាជិក
១០- ឯកឧត្តម **ហេង សុខគង់** រដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម សមាជិក
១១- ឯកឧត្តម **ជា ច័ន្ទបរិបូរណ៍** រដ្ឋលេខាធិការក្រសួងព័ត៌មាន សមាជិក
១២- ឯកឧត្តម **ទិត ចន្ថា** រដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក
១៣- ឯកឧត្តម **ជូ យិនស៊ឹម** រដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក
១៤- លោកជំទាវ **ម៉ុញ ភុសនី** រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សមាជិក
១៥- ឯកឧត្តម **ទី សុគន្ធ** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសមាជិក
១៦- លោកជំទាវ **គឹម សេដ្ឋានី** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា សមាជិក
១៧- លោកជំទាវ **សេង វណ្ណសាយ** រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម សមាជិក
១៨- ឯកឧត្តម **សុខ ខាវ៉ាន់** រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល សមាជិក
១៩- ឯកឧត្តម **ភាន ចាន់មេត្តា** រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សមាជិក
២០- ឯកឧត្តម **ម៉ៅ ហាវណ្ណាល់** រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សមាជិក
២១- ឯកឧត្តម នាយឧត្តមសេនីយ៍ **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ សមាជិក
២២- ឯកឧត្តម នាយឧត្តមសេនីយ៍ **សៅ សុខា** មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
២៣- ឯកឧត្តម **ជា វុទ្ធី** អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា សមាជិក
២៤- ឯកឧត្តម **ស៊ុំ ម៉ាប់** អគ្គនាយកនៃអាជ្ញាធរជាតិអប្សរា សមាជិក
២៥- ឯកឧត្តម **វ៉េង សុផល្លែត** អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន សមាជិក
២៦- ឯកឧត្តម **ប៉ា សុជាតិវង្ស** អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ សមាជិក
២៧- ឯកឧត្តម **ឃឹម ប៊ុនសុខ** អភិបាលនៃគណៈអភិបាលខេត្តសៀមរាប សមាជិក
២៨- ឯកឧត្តម **កែវ សិរីបុត្រ** អគ្គលេខាធិការរង គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ សមាជិក
២៩- ឯកឧត្តម **ហ៊ុន ម៉ានី** ប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា(ស.ស.យ.ក)សមាជិក

**ប្រការ២ .-**

គណៈកម្មការអន្តរក្រសួងរៀបចំកិច្ចប្រជុំវេទិកាសេដ្ឋកិច្ចពិភពលោកស្តីពីអាស៊ាន ឆ្នាំ២០១៧ មានភារកិច្ចដឹកនាំ ចាត់ចែង និងត្រួតពិនិត្យដំណើរការរៀបចំកិច្ចប្រជុំវេទិកាសេដ្ឋកិច្ចពិភពលោកស្តីពីអាស៊ានឆ្នាំ ២០១៧ ឱ្យមានប្រសិទ្ធភាព និងទទួលបានជោគជ័យ។ គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិបង្កើតលេខាធិការដ្ឋាន អនុគណៈកម្មការ ឬក្រុមការងារបន្ថែម តាមការចាំបាច់។

គណៈកម្មការអន្តរក្រសួងនេះ អាចអញ្ជើញតំណាងក្រសួង-ស្ថាប័ន វិស័យឯកជន ឥស្សរជនជាតិ-អន្តរជាតិ ឬភាគីពាក់ព័ន្ធផ្សេងទៀត ដើម្បីពិគ្រោះយោបល់ ឬចូលរួមក្នុងកិច្ចប្រជុំរបស់ខ្លួន ឬចូលរួមក្នុងការងារសិក្សាស្រាវជ្រាវ និងផ្តល់យោបល់ តាមការចាំបាច់។

**ប្រការ៣ .-**

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់ថវិកាដោយឡែករបស់ក្រសួងសាធារណការនិងដឹកជញ្ជូន និងប្រភពថវិកាស្របច្បាប់ផ្សេងៗទៀត ដើម្បីដំណើរការការងាររបស់ខ្លួន។ គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិស្វែងរកដៃគូអភិវឌ្ឍន៍ ឬផ្នែកឯកជន ដើម្បីជួយទ្រទ្រង់និងឧបត្ថម្ភដល់ដំណើរការរៀបចំកិច្ចប្រជុំវេទិកាសេដ្ឋកិច្ចពិភពលោកស្តីពីអាស៊ាន ឆ្នាំ២០១៧នេះ។

**ប្រការ៤ .-**

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់ត្រា និងក្បាលលិខិតដែលមានសញ្ញាសម្គាល់របស់ក្រសួងសាធារណការនិងដឹកជញ្ជូន ដើម្បីដំណើរការការងាររបស់ខ្លួនតាមការចាំបាច់។

**ប្រការ៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ អភិបាលនៃគណៈអភិបាលខេត្តសៀមរាប និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តតាមសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ទុ៧ ឆ្នាំ២០១៦

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**អន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ